**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ២៥២
ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៣
**សាលដីកា**
លេខៈ ១២៤
ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម ............ ជាប្រធាន
២-លោក .............. ជាចៅក្រម
៣-លោក ................. ជាចៅក្រម
៤-លោក ............... ជាចៅក្រមរបាយការណ៍
៥-លោក ................ ជាចៅក្រម

**ក្រឡាបញ្ជី**
-កញ្ញា ..................

**តំណាងមហាអយ្យការ**
-លោក .............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្ដឹងសាទុក្ខពីសាលដីកា ០៨(ច) ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៧១៦ចុះថ្ងៃទី ០៧ ខែវិច្ឆកា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍រវាងៈ

ដើមចោទឈ្មោះ ជក ចុងបណ្ដឹងសាទុក្ខ ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរមុខរបរ កងរាជអាវុធហត្ថលើផ្ទៃប្រទេស ទីលំនៅ ផ្ទះលេខ ៣២៦Eo ផ្លូវព្រះសីហនុ សង្កាត់អូឡាំពិក ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ខេង ជុង ( រ ) ម្ដាយឈ្មោះ សៀង ហួង ( រ ) ប្រពន្ធ ឈ្មោះ សុ មាលី ។

មានមេធាវី លោក សចឧណ

និងចុងចម្លើយឈ្មោះ ឈវត ដើមបណ្ដឹងសាទុក្ខ ភេទស្រី អាយុ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅផ្ទះលេខ ៤៤ ផ្លូវនរោត្តម សង្កាត់ផ្សារថ្មី២ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មានមេធាវីលោក .............

***អំពីរឿងៈ*** ប្ដឹងទាមទារប្រាក់ ១០០០០ដុល្លាអាមេរិក ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៥២ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

បានឃើញបណ្តឹងសាទុក្ខលេខ១៣៣ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០០៣ របស់អ្នកស្រី ឈវត មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៨(ច) ចុះថ្ងៃទី២៣ ខែ មករា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុចនៃសាលដីកាទាំងមូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ០៧-៧-២០០០ របស់ឈ្មោះ ជក ប្តឹងទាមទារប្រាក់ចំនួន ១០០០០ ដុល្លាអាមេរិក ពីឈ្មោះ ឈវត ដោយសំអាងហេតុថា អ្នកស្រីឈវត បានខ្ចីចងការប្រាក់ចំនួន ១០០០០ដុល្លាអាមេរិក តាមកិច្ចសន្យា ចុះថ្ងៃទី ១៩-៣-២០០០ ហើយឈ្មោះ ឈវត ពុំបានសងនិង បង់ការប្រាក់ឱ្យខ្លួន តាំងពីថ្ងៃទី ១៩-៤-២០០០ រហូតមកដល់សព្វថ្ងៃ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៦៧(ខ) ចុះថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ ២០០០ របស់ តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងរបស់លោក ជក ដើមចោទ ចុះថ្ងៃទី ០៧-៧-២០០០ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- បង្គាប់ឱ្យអ្នកស្រីឈវត សងប្រាក់ចំនួន៩៦៤២$US និង ការប្រាក់ ៥% ក្នុងរយៈពេល ១ឆ្នាំ គិតចាប់ពីថ្ងៃទី ២០-៤-២០០០ រហូតដល់ថ្ងៃសងរួច ព្រមទាំងជម្ងឺចិត្តចំនួន៥០០$US ឱ្យទៅលោកជក សំណូមពរលើសពីនេះបដិសេធចោល ។

ក្នុងករណីអ្នកស្រី ឈវត ពុំព្រមសងប្រាក់ទេ ទៅលោក ជក ទេ ត្រូវរឹបអូសទ្រព្យសម្បត្តិលក់ជានាសំណងហើយបើរឹងទទឹងពុំព្រមសងត្រូវដាក់គុកបង្ខំរូបកាយ តាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៣- បង្គាប់ឱ្យអ្នកស្រីឈវត បង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តីនិងពន្ធហ្វឹង១៨០០រៀល រង្វាន់ ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០រៀល បូករួម ៧០០០រៀល ប្រាក់នេះកាត់យកពីប្រាក់ ៧០០០៛ ដែលដើមចោទបង់ទុករួចហើយ ។

កាលបើផុតកំណត់បណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យអ្នកស្រី ឈវត សងប្រាក់ ៧០០០រៀល ទៅ ដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រ១ភាគរយ លើទឹកប្រាក់ត្រូវសងទាំងអស់ ហើយប្រាក់នេះ ត្រូវបង់ចូល ថវិការដ្ឋ ៨០% និង បានជារង្វាន់ក្រឡាបញ្ជីទាំងប្រទេស២០% ។

៤- សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវបណ្តឹង ទាស់ និងបណ្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងទាស់ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០០ របស់អ្នកស្រី ឈវត (ពាក្យបណ្តឹងចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០០០) មិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៦៧ (ខ) ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០០ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៥៥ (ខ) ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០១ របស់ តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងទាស់ របស់អ្នកស្រី ឈរតែ ដើមបណ្តឹងទាស់ ចុះថ្ងៃទី ២៨-១២-២០០០ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៦៧(ខ) ចុះថ្ងៃទី ១៤-១២-២០០០ របស់តុលាការក្រុង ភ្នំពេញ ទុកជាបានការតាមច្បាប់តទៅ ។

៣- សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខចុងចម្លើយនៃបណ្តឹងទាស់ កំបាំងមុខដើមបណ្តឹង ទាស់ទុកដូចជាចំពោះមុខ បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ២៩(ខ) ចុះថ្ងៃទី៣០ ខែ កក្កដា ឆ្នាំ ២០០១ របស់អ្នកស្រី ឈរតែ មិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៥៥(ខ) ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០១ របស់តុលាការ ក្រុងភ្នំពេញ លើសេចក្តីសម្រេច នៃសាលក្រមទាំងមូល ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ១៣៧ (ច) ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣០-០៧-២០០១ របស់ឈ្មោះ ឈរតែ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-កម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៥៥(ខ) ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ចំនួន ១៣,០០០៛ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន២៥៥០ រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ៥០០០រៀល ។

៤-សាលដីការនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវី តំណាងដើមចោទ កំបាំងមុខចុងចម្លើយ ។បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ១៦៨ ចុះថ្ងៃទី២៩ ខែតុលាឆ្នាំ២០០២ របស់អ្នកស្រី ឈរតែ (ពាក្យបណ្តឹងចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០២ )មិនសុខចិត្តនឹងសាលដីការរដ្ឋប្បវេណីលេខ ១៣៧ (ច) ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការរដ្ឋប្បវេណីលេខ ០៨(ច) ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី២៩ ខែតុលាឆ្នាំ២០០២ របស់ឈ្មោះ ឈរតែ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ ១៣៧ (ច) ចុះថ្ងៃទី១៤ ខែតុលាឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ តែចាត់ទុកជាចំពោះមុខ ។បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ១៣៣ ចុះថ្ងៃទី១៤ខែមីនា ឆ្នាំ២០០៣ របស់អ្នកស្រី ឈវត មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ០៨ (ច) ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍លើត្រង់ចំណុច នៃសាលដីកាទាំងមូល ។

បានឃើញសារណាការពាររបស់អ្នកស្រី ឈវត ចុះថ្ងៃទី១៩ ខែកញ្ញាឆ្នាំ២០០៣

បានឃើញសារណាតបរបស់មេធាវី លោក សចឧណតំណាងឲ្យលោកជុក កេង ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ ២០០៣

បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការថាៈ

-បណ្ដឹងសាទុក្ខរបស់ចុងចម្លើយ ស្ថិតក្នុងកំណត់ច្បាប់គប្បីលើកយកមកពិនិត្យពិចារណា ។

-សាលដីការដ្ឋប្បវេណីលេខ ០៨ (ច) ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។

កាឡាបញ្ជីអានសារណា ការពារ របស់អ្នកស្រី ឈវត

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី លោក សចឧណការពារឲ្យដើមចោទបញ្ជាក់ថាៈ

តាមការព្រមព្រៀងរបស់កូនក្ដីខ្លួន ជាម្ចាស់បំណុល និងអ្នកស្រី ឈវត ជាកូនបំណុលដោយមានកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០០ ដែលក្នុងនាមម្ចាស់បំណុលបានប្រគល់ប្រាក់ឲ្យគេខ្ចីគ្រប់ចំនួនប៉ុន្តែកូនបំណុលវិញគឺជាអ្នកពុំបានបំពេញតាមកាតព្វកិច្ចរបស់ខ្លួនឡើយ ក្នុងកិច្ចសន្យា ។ ម្យ៉ាងទៀត អ្នកស្រីបានឆ្លើយក្នុងសារណារបស់គាត់បង្ហាញថាពុំមានការប៉ះពាល់ដល់ការខ្ចីប្រាក់នេះជាមួយក្រុមហ៊ុនឡើយ គឺអ្នកស្រីបាន ខ្ចីតែម្នាក់ឯងទេ ប៉ុន្តែយកមកបំរើផលប្រយោជន៍ក្រុមហ៊ុន LT Luxe ទាំងអស់គ្នានោះ ពុំមែនជាការត្រឹមត្រូវទេ ពីព្រោះបំណុលនេះ ពុំមានជាប់ពាក់ព័ន្ធ និង ក្រុមហ៊ុន LT Luxe រឺក៏ឈ្មោះ ថវឡទ្បើយ ដោយក្រុមហ៊ុន នេះ បានលុបចេញពីបញ្ជីពាណិជ្ជកម្ម តាំងពីថ្ងៃទី១១ខែវិច្ឆកា ឆ្នាំ១៩៩៩ មកម្លេះ ។

ដំបូងគឺអ្នកស្រី ឈវត និង លោក ថវឡបានខ្ចីប្រាក់ពីកូនក្ដីរបស់ខ្លួនចំនួន ១០០០០ដុល្លា ដែលមានកិច្ចសន្យាចុះថ្ងៃទី១៥-១២-១៩៩៨ រួចហើយក៏គាត់បានយកប្រាក់នេះ ទៅឱ្យគេខ្ចីបន្តផ្សេងទៀត ដោយ គាត់យកតែការប្រាក់ទេ ។ ក្រោយមកគេក៏បានសងលុយនោះមកវិញគ្រប់ចំនួនហើយ ប៉ុន្តែអ្នកស្រី ឈវត តែម្នាក់ឯងបានខ្ចីប្រាក់នេះបន្តពីកូនក្ដីរបស់ខ្លួនម្ដងទៀត តាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ១៩-៣-២០០០ ។

សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាតម្កល់សាលដីកា របស់សាលាឧទ្ធរណ៍ ទុកជាបានការ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់ចុងចម្លើយ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវី ដើមចោទ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៣៣ ចុះថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០៣ របស់អ្នកស្រី ឈវត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានដោយយោងតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលអ្នកស្រី ឈវត លើកឡើងក្នុងសារណាការពាររបស់ខ្លួន ចុះថ្ងៃទី ១៩-៩-២០០៣ នោះគឺជាការភ័ន្តច្រឡំ ពីព្រោះ ថា ៖

អ្នកស្រីឈវត បានទទួលស្គាល់ខ្លួនឯងថាពិតជាជំពាក់ប្រាក់ លោកជក ចំនួន មួយម៉ឺនដុល្លាអាមេរិក ដូចមានក្នុងកិច្ចសន្យា ចុះថ្ងៃទី ១៩ ខែមិនា ឆ្នាំ ២០០០ ពិតប្រាកដមែន ។ ម៉្យាងវិញទៀត អ្នកស្រី ឈវត ក៏បានទទួលស្គាល់ថា បានបង់ការប្រាក់ជូនលោកជក កន្លងមកបាន ៤០០ដុល្លាអាមេរិក(បួនរយដុល្លាអាមេរិក) ហើយដែល លោក ជក ក៏បានទទួលស្គាល់ដូច្នេះដែរ ។ ហេតុនេះ តាមមាត្រា២២និង២៩ នៃក្រឹត្យច្បាប់លេខ ៣៨ក្រច ចុះថ្ងៃទី២៨ ខែ តុលា ឆ្នាំ ១៩៨៨ អ្នកស្រីឈវត មានកាតព្វកិច្ចអនុវត្តនូវកិច្ចសន្យារបស់ខ្លួនខាងលើនេះហើយ ។

- យល់ឃើញថា ការដែលអ្នកស្រី ឈវត លើកឡើងក្នុងសារណាថា តាមអំណាចសាលដីកាស្តាពរបស់តុលាការកំពូល គប្បីបង្អង់រឿងនេះសិន ទុករង់ចាំតុលាការក្រុងភ្នំពេញ ធ្វើការបែងចែកទ្រព្យសម្បត្តិរួចសិនចាំយករឿងបំណុលនេះ មកដោះស្រាយនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះ តាមកិច្ចសន្យា ចុះថ្ងៃទី ១៩-០៣-២០០០ អ្នកស្រីខ្ចីប្រាក់នេះ ពុំមែនក្នុងនាមក្រុមហ៊ុនទេហើយតាមកិច្ចសន្យានេះអ្នកស្រីសន្យាសងត្រឹមថ្ងៃទី១៥-១២-២០០០ប៉ុណ្ណោះ ។

- យល់ឃើញថា គូភាគីបានធ្វើសារណាជូនមកតុលាការកំពូល រួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីដើមចោទមកចូលរួម ដូច្នេះតុលាការកំពូល ជំនុំជំរះកំបាំងមុខគូក្តី ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ០៨(ច) ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីកំបាំងមុខគូក្តី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ ១៣៣ ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៣ របស់ អ្នកស្រី ឈវតទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ០៨(ច) ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀលដែលលោក ដក បានបង់ទុកនៅតុលាការកំពូលគឺៈ

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ៤០០០៛ ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ហើយតម្រូវឱ្យអ្នកស្រី ឈវត សងប្រក់ចំនួន ១៩.០០០រៀល នេះ ទៅលោក ដក វិញ ។

បង្គាប់ឱ្យអ្នកស្រី ឈវត បង់ពន្ធសមាមាត្រ មួយភាគរយលើប្រាក់ដែលត្រូវសងដើមចោទ។

៤- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០០៤